# សេចក្តីសង្ខេបករណីសិក្សា Case.5

## ១. ការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

នៅថ្ងៃទី១ ខែតុលា ឆ្នាំ២០១៩ X បានបង្កើតកិច្ចសន្យាខ្ចីបរិភោគប្រាក់ចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល ដោយយកការប្រាក់ ចំនួន ៥ ភាគរយ (ប្រាំភាគរយ) ក្នុងមួយឆ្នាំ និងកំណត់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ ជាពេលកំណត់សងជាមួយ Y ហើយបានប្រគល់សាច់ប្រាក់ចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល ទៅឱ្យ Y។ កិច្ចសន្យានេះ ត្រូវបានធ្វើឡើងដោយលាយល័ក្ខណ៍អក្សរនៃលិខិតកិច្ចសន្យា ដោយមានចុះហត្ថលេខារបស់ភាគីទាំងពីរ។

កាលកំណត់អំឡុងពេលសងថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ បានកន្លងផុត ដោយសារតែ Y មិនបានសងទាល់តែសោះ ទើប X បានទាមទារឱ្យសងជាច្រើនលើកច្រើនសារទៅកាន់ Y ចាប់ពីអំឡុងខែតុលា ឆ្នាំ២០២០។ ប៉ុន្តែ Y មិនបានធ្វើការឆ្លើយតបទេ រហូតមកដល់អំឡុងដើមខែវិច្ឆិកា ឆ្នាំ២០២០ សូម្បីទាក់ទងក៏លែងបានដែរ។

X បានឮពីអ្នកដែលបានស្គាល់ Y ថា Y មានអាជីវកម្មហាងបោកអ៊ុត ប៉ុន្តែ អាជីវកម្មនោះមិនបានដំណើរទៅដោយយ៉ាងរលូននោះទេ ហើយលើសពីនេះបានខ្ចីប្រាក់ពីសាច់ញាតិ និងអ្នកស្គាល់គ្នាជាច្រើនទៀតផង។ ម្យ៉ាងវិញទៀត ក្រៅពីដីដែលមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ (តម្លៃ ប្រហែល ១៥.០០០ (មួយម៉ឺនប្រាំពាន់) ដុល្លាអាមេរិក) រកមិនឃើញទ្រព្យសម្បត្តិផ្សេងទៀតមានតម្លៃនោះទេ។

អាស្រ័យហេតុនេះ បានពឹងពាក់មេធាវី P ហើយបានដាក់ពាក្យសុំរឹបអូសជាបណ្តោះអាសន្នចំពោះដីដែលមានសរសេរក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុដែលជាកម្មសិទ្ធិរបស់ Y ដើម្បីរក្សាការពារការអនុវត្តដោយបង្ខំនូវសិទ្ធិលើបំណុលដែលទាមទារផ្អែកតាមកិច្ចសន្យានៃរឿងក្តីនេះ។

## ២. ការអនុវត្តចំពោះអចលនវត្ថុ

នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០ X បានពឹងពាក់មេធាវី P ហើយបានដាក់បណ្ដឹងទាមទារឱ្យសងប្រាក់ផ្អែកតាមកិច្ចសន្យានៃរឿងក្ដីនេះទៅកាន់ Y។ នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១ តុលាការបានចេញសាលក្រមដែលមានអត្ថន័យទទួលស្គាល់នូវការទាមទាររបស់ X ហើយសាលក្រមដដែលនេះបានចូលជាស្ថាពរ នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១។ លើសពីនេះទៀត ទោះបីជាក្រោយពីសាលក្រមបានចូលជាស្ថាពរក៏ដោយ ក៏ Y មិនបានសងប្រាក់កម្ចីមក X ទាល់តែសោះ។

ដូច្នេះហើយ X បានពឹងពាក់មេធាវី P ហើយបានដាក់ពាក្យសុំឱ្យចាប់ផ្ដើមនីតិវិធីដេញថ្លៃលក់ដោយបង្ខំចំពោះដីដែលមានសរសេរក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុដែលជាកម្មសិទ្ធិរបស់ Y ផ្អែកតាមសាលក្រមខាងលើ។